- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ .-** បង្កើតស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ .-** ស្ថានអគ្គកុងស៊ុលនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មកុងស៊ុលម្នាក់ ដែលមានឋានៈជាអគ្គកុងស៊ុល ។

**មាត្រា ៣ .-** សមាសភាពមន្ត្រីកុងស៊ុលផ្សេងៗទៀត យ៉ាងច្រើនបំផុត ០២ នាក់ នឹងត្រូវកំណត់តាមលក្ខការណ៍កុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនកុងស៊ុលទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៤ .-** ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និង បុគ្គលិក នៃស្ថានអគ្គកុងស៊ុលនេះ នឹងស្ថិតក្នុងក្របខ័ណ្ឌ " ខ " ។

**មាត្រា ៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៣៣ អនក្រ.បក

## ស្តីពីការបង្កើតស្ថានអគ្គកុងស៊ុល

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ ._ បង្កើតស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ ._ ស្ថានអគ្គកុងស៊ុលនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មកុងស៊ុលម្នាក់ ដែលមានឋានៈជាអគ្គកុងស៊ុល ។

មាត្រា ៣ ._ សមាសភាពមន្ត្រីកុងស៊ុលផ្សេងៗទៀត យ៉ាងច្រើនបំផុត ០២ នាក់ នឹងត្រូវកំណត់តាមលក្ខការណ៍កុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនកុងស៊ុលទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ ._ ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និង បុគ្គលិក នៃស្ថានអគ្គកុងស៊ុលនេះ នឹងស្ថិតក្នុងក្របខ័ណ្ឌ " ខ " ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ១០០ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី